១៦៧

តុលាការក្រុងភ្នំពេញ

~~~~~~~

សំណុំរឿងព្រហ្មទណ្ឌលេខ
: ១៧៦១ ចុះថ្ងៃទី ២២ ខែ
សីហា ឆ្នាំ ២០០៦

សាលក្រមលេខ : ៨៤ ខ
ចុះថ្ងៃទី ០៩-០៣-២០០៧

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

\*\*\*\*\*\*\*\*

# តាងនាមប្រជារាស្ត្រខ្មែរ

## តុលាការក្រុងភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា ដែលប្រកាសឱ្យប្រើតាមក្រឹត្យ លេខ ០៦ក្រ ចុះថ្ងៃទី ០៨-០២-១៩៩៣ ។

បានបើកសវនាការជាសាធារណៈ នាថ្ងៃទី ១៦-០២-២០០៧ ដោយមានសមាសភាពដូចតទៅ :

**ចៅក្រមជំនុំជំរះ**

- លោក [redacted] អនុប្រធានតុលាការក្រុងភ្នំពេញ

**តំណាងអយ្យការ**

- លោក [redacted] ព្រះរាជអាជ្ញារងអមតុលាការក្រុងភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

- លោក [redacted] ក្រឡាបញ្ជីសវនាការ

**ដើម្បីជំនុំជំរះ**

សំណុំរឿងព្រហ្មទណ្ឌលេខ:១៧៦១ ចុះថ្ងៃទី ២២-០៨-២០០៦ ដែលមានជនជាប់ចោទ :

១-ឈ្មោះ [redacted] ធីយីវ ភេទស្រី អាយុ២២ឆ្នាំ ជាតិវៀតណាម កើតនៅប្រទេសវៀតណាម សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃផ្ទះជួលនៅផ្[redacted]សង្កាត់ផ្សារដេប៉ូ២ ខណ្ឌទួលគោក ក្រុងភ្នំពេញ របររកស៊ីនៅផ្ទះ ឪពុក ឈ្មោះ [redacted] ស ម្តាយឈ្មោះ [redacted] រ ប្តីឈ្មោះ [redacted] មានកូន ០ នាក់ ទោសពីមុនគ្មាន ចាប់ខ្លួនថ្ងៃទី ១៩-០៨-២០០៦ ឃុំខ្លួនថ្ងៃទី ២៥ ខែ ០៨ ឆ្នាំ ២០០៦ លេខឃុំខ្លួន១២៦៥ ។

២-ឈ្មោះ [redacted] ធី ភេទស្រី អាយុ៤៨ឆ្នាំ ជាតិវៀតណាម កើតនៅស្រុកក្រគរ ខេត្តពោធិសាត់ សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃ[redacted] ខណ្ឌមានជ័យ ក្រុងភ្នំពេញ របររកស៊ីជាងឆាបរណា ឪពុកចម៉ឈ្មោះ [redacted] រ [redacted] រ ប្តីឈ្មោះ[redacted] មានកូន ០៣ នាក់ ទោសពីមុនគ្មាន ចាប់ខ្លួនថ្ងៃទី១៩-០៨-២០០៦ ឃុំខ្លួន ថ្ងៃទី ២៥ ខែ ០៨ ឆ្នាំ២០០៦ លេខឃុំខ្លួន ១២៤៥ ។

៣-ឈ្មោះ [redacted] ហុងវីង ភេទប្រុស អាយុ២០ឆ្នាំ ជាតិវៀតណាម កើតនៅប្រទេសវៀតណាម សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃផ្ទះជួល [redacted] ខណ្ឌទួលគោក ក្រុងភ្នំពេញ របររកស៊ីជាងម៉ូតូ ឪពុកឈ្មោះ[redacted] ស ម្តាយឈ្មោះ [redacted] រ ប្រពន្ធឈ្មោះ[redacted] មានកូន ០ នាក់ ទោសពីមុនគ្មាន ចាប់ខ្លួនថ្ងៃទី ១៩-០៨-២០០៦ ឃុំខ្លួនថ្ងៃទី២៥ ខែ០៨ ឆ្នាំ២០០៦ លេខឃុំខ្លួន១២៤៦ ។

៤-ឈ្មោះ [redacted]Heninz ភេទប្រុស អាយុ៦១ឆ្នាំ ជាតិអាឡឺម៉ង់ កើតនៅប្រទេសអាឡឺម៉ង់ ទីលំនៅសព្វថ្ងៃផ្ទះលេ[redacted]សង្កាត់បឹងកេងកង១ ខណ្ឌចំការមន ក្រុងភ្នំពេញ របររកស៊ីគ្រូបង្រៀន ឪពុកឈ្មោះ [redacted] ស ម្តាយឈ្មោះ [redacted] រ នៅលើវ ទោសពីមុនគ្មាន ចាប់ខ្លួនថ្ងៃទី១៩-០៨-២០០៦ ឃុំខ្លួនថ្ងៃទី-



Scanned by CamScanner
~~~~~~~

២៨ ខែ០៨ ឆ្នាំ២០០៦ លេខឃុំខ្លួន១២៦៥ ។

ជាប់ចោទពីបទ **ជួញដូរមនុស្ស** ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃខែ ០៧.០៨ ឆ្នាំ២០០៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣ នៃច្បាប់ស្តីពីការបង្ក្រាបអំពើពង្រាត់និងលក់ដូរមនុស្ស និងអំពើធ្វើអាជីកម្មលើមនុស្ស ។

១-ឈ្មោះ [redacted]Heninz ភេទប្រុស អាយុ៦០ឆ្នាំ ជាតិអាឡឺម៉ង់ កើតនៅប្រទេសអាឡឺម៉ង់ ទីលំនៅសព្វថ្ងៃផ្ទះលេខ[redacted]១ ខណ្ឌចំការមន ក្រុងភ្នំពេញ របររកស៊ីគ្រូបង្រៀន ឪពុកឈ្មោះ [redacted] ស ម្តាយឈ្មោះ[redacted] ស នៅលីវ ទោសពីមុនគ្មាន ចាប់ខ្លួនថ្ងៃទី១៩-០៨-២០០៦ ឃុំខ្លួនថ្ងៃទី ២៨ ខែ០៨ ឆ្នាំ២០០៦ លេខឃុំខ្លួនលេខ១២៦៥ ។

២-ឈ្មោះ [redacted] thomas ភេទប្រុស អាយុ៤២ឆ្នាំ ជាតិអាឡឺម៉ង់ កើតនៅប្រទេសអាឡឺម៉ង់ ទីលំនៅសព្វថ្ងៃផ្ទះ[redacted]៦ ខណ្ឌចំការមន ក្រុងភ្នំពេញ របររកស៊ីគ្រូបង្រៀន ឪពុកឈ្មោះ [redacted] រ ម្តាយឈ្មោះ [redacted] រ ប្រពន្ធឈ្មោះ [redacted] មានកូន០១នាក់ ទោសពីមុនគ្មាន ចាប់ខ្លួនថ្ងៃទី២១-០៨-២០០៦ ឃុំខ្លួនថ្ងៃទី២៥ ខែ០៨ ឆ្នាំ២០០៦ លេខឃុំខ្លួន ១២៤៦ ។

ជាប់ចោទពីបទ **ប្រព្រឹត្តអំពើអនាចារលើកុមារ** ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃខែ ០៧.០៨ ឆ្នាំ២០០៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៨ នៃច្បាប់ស្តីពីការបង្ក្រាបអំពើពង្រាត់និងលក់ដូរមនុស្ស និងអំពើធ្វើអាជីកម្មលើមនុស្ស ។

**ជនរងគ្រោះ :**

១-ឈ្មោះ[redacted]ធី ភេទស្រី អាយុ១២ឆ្នាំ ជនជាតិវៀតណាម កើតនៅប្រទេសឡាវ សាសនាព្រះពុទ្ធ ទីលំនៅភូមិដើមចាន់ ផ្លូវ៣៦៩ សង្កាត់ច្បារអំពៅ២ ខណ្ឌមានជ័យ ក្រុងភ្នំពេញ ។

២-ឈ្មោះ [redacted]ថា ភេទស្រី អាយុ១៤ឆ្នាំ ជនជាតិវៀតណាម កើតនៅប្រទេសឡាវ សាសនាព្រះពុទ្ធ ទីលំនៅភូមិដើមចាន់ ផ្លូវ៣៦៩ សង្កាត់ច្បារអំពៅ២ ខណ្ឌមានជ័យ ក្រុងភ្នំពេញ ។

៣-ឈ្មោះ[redacted]យ៉ុង ភេទស្រី អាយុ១៣ឆ្នាំ ជនជាតិវៀតណាម កើតនៅ សង្កាត់ច្បារអំពៅ២ ខណ្ឌមានជ័យ ក្រុងភ្នំពេញ សាសនាព្រះពុទ្ធ ទីលំនៅភូមិច្រាំងចាក់ សង្កាត់ច្បារអំពៅ២ ខណ្ឌមានជ័យ ក្រុងភ្នំពេញ ។

៤-ឈ្មោះ [redacted] យីវ ភេទស្រី អាយុ១៤ឆ្នាំ ជនជាតិវៀតណាម កើតនៅប្រទេសវៀតណាម សាសនាព្រះពុទ្ធ ទីលំនៅ សង្កាត់ច្បារអំពៅ២ ខណ្ឌមានជ័យ ក្រុងភ្នំពេញ ។

-លោកស្រី [redacted]ជារត្ន័ ជាមេធាវី នៃព្រះរាជាណាចក្រកម្ពុជា ការពារជនរងគ្រោះទាំង៤នាក់ ។

-លោក [redacted]ហាក់. លោក [redacted] តុលា. លោក [redacted] គីម ជាមេធាវីក្រុមមេធាវីកម្ពុជាអន្តរជាតិ ការពារឱ្យជនជាប់ ឈ្មោះ [redacted]thomas

-លោក [redacted]អ៊ី ជាមេធាវីក្រុមមេធាវីអង្គ ការពារឱ្យជនជាប់ឈ្មោះ[redacted]

-លោក[redacted]ចន្ថា ជាមេធាវី នៃសមាជិកគណៈមេធាវី ការពារឱ្យជនជាប់ឈ្មោះ [redacted]Heninz

-លោក [redacted] ឡុង និង [redacted] ហុង ជាមេធាវី នៃសមាជិកគណៈមេធាវី ការពារឱ្យជនជាប់ ឈ្មោះ [redacted]



Scanned by CamScanner

ហុងវីង ឈ្មោះ[redacted]ទី ឈ្មោះ [redacted] ធីយ៉ីវ

## ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ

កាលពីខែ ០៧-០៨ ឆ្នាំ២០០៦ នៅក្រុងភ្នំពេញ មានករណីជួញដូរមនុស្សដែលបង្កឡើងដោយឈ្មោះ [redacted] **Heninz** ភេទប្រុស អាយុ៦០ឆ្នាំ ជាតិអាឡឺម៉ង់ និង ឈ្មោះ [redacted] **ហុងវីង** ភេទប្រុស អាយុ២០ឆ្នាំ ជាតិវៀតណាម និង ឈ្មោះ [redacted] **ធីយ៉ីវ** ភេទស្រី អាយុ២១ឆ្នាំ ជាតិវៀតណាម និង ឈ្មោះ[redacted] **ទី** ភេទស្រី អាយុ៤៦ឆ្នាំ ជាតិវៀតណាម និងគូកន ។ ហើយក្នុងខែកក្កដា .សីហា ឆ្នាំ២០០៦ ក៏មានករណីប្រព្រឹត្តអំពើអនាចារលើកុមារ នៅក្រុងភ្នំពេញ ដែលបង្កឡើងដោយឈ្មោះ [redacted]**Heninz** ភេទប្រុស អាយុ៦០ឆ្នាំ ជាតិអាឡឺម៉ង់ និង ឈ្មោះ [redacted] **thomas** ភេទប្រុស អាយុ៤២ឆ្នាំ·ជាតិអាឡឺម៉ង់ ក្នុងរឿងនេះមានជនរងគ្រោះ ឈ្មោះ[redacted]**ចាន់ធី** ភេទស្រី អាយុ១២ឆ្នាំ ជនជាតិវៀតណាម ឈ្មោះ [redacted]**ចាន់ថា** ភេទស្រី អាយុ១៤ឆ្នាំ ជនជាតិវៀតណាម ឈ្មោះ[redacted]**គីមយ៉ុង** ភេទស្រី អាយុ១៣ឆ្នាំ ជនជាតិវៀតណាម ឈ្មោះ[redacted] **យ៉ីវ** ភេទស្រី អាយុ១៤ឆ្នាំ ជនជាតិវៀតណាម ។

កាលពីថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៦ ការិយាល័យប្រឆាំងការជួញដូរមនុស្សក្រុងភ្នំពេញ បានឃាត់ខ្លួន ឈ្មោះ [redacted] **ហុងវីង** ភេទប្រុស និង ឈ្មោះ [redacted] **ធីយ៉ីវ** ភេទស្រី ដែលកំពុងនាំកុមារី ឈ្មោះ [redacted]**គីមយ៉ុង** ភេទស្រី អាយុ១៣ឆ្នាំ ទៅឱ្យជនបរទេស ដែលមានអាសយដ្ឋានផ្ទះលេខ១៦E2 ផ្លូវ២៧៨ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន ក្រុងភ្នំពេញ ហើយនៅថ្ងៃនោះដែលសមត្ថកិច្ចបានឃាត់ខ្លួន ឈ្មោះ [redacted] **ទី** ភេទស្រី ដែលត្រូវជាម្តាយ ឈ្មោះ [redacted] **ចាន់ធី** និង ឈ្មោះ[redacted] **ចាន់ថា** ។ ក្រោយពីសួរចំលើយឈ្មោះ[redacted] **ហុងវីង** និង ឈ្មោះ [redacted] **ធីយ៉ីវ** និង ឈ្មោះ [redacted] **ទី** សមត្ថកិច្ចបានធ្វើការឆែកឆេរផ្ទះលេខ១៦E2 ផ្លូវ២៧៨ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន ក្រុងភ្នំពេញ ថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៦ និង ផ្ទះលេខ៣៦ CE1 ផ្លូវ២៧៨ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន ក្រុងភ្នំពេញ ថ្ងៃទី២១ ខែសីហា ឆ្នាំ២០០៦ ដោយបានដកហូតរូបថតអាសអាភាសមួយចំនួន និងវត្ថុតាងផ្សេងទៀតព្រមទាំងឃាត់ខ្លួនជនបរទេសឈ្មោះ [redacted]**Heninz** ភេទប្រុស អាយុ៦០ឆ្នាំ ជាតិអាឡឺម៉ង់ និងឈ្មោះ [redacted] **thomas** ភេទប្រុស អាយុ៤២ឆ្នាំ ជាតិអាឡឺម៉ង់ ។

បានឃើញរបាយការណ៍សំយោគ របស់ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន លេខ ២៨៤-០៦ ចុះថ្ងៃទី ២២-០៨-០៦ ។

បានឃើញរបាយការណ៍របស់អង្គការសកម្មភាពដើម្បីកុមារលេខ០៣១សដក/០៦ចុះថ្ងៃទី២៤-០៧-២០០៦ ។

បានឃើញរបាយការណ៍ស៊ើបអង្កេតរបស់មន្ត្រីជំនាញ របស់ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការការពារអនីតិជន ចុះថ្ងៃទី ២២-០៨-០៦ ។

បានឃើញដីកាឆែកឆេរលំនៅដ្ឋានលេខ១៣៧អយយ ចុះថ្ងៃទី ២០-០៨-០៦ និង លេខ១៣៨អយយ ចុះថ្ងៃទី ២១-០៨-០៦ របស់តំណាងអយ្យការអមតុលាការក្រុងភ្នំពេញ ។

បានឃើញកំណត់ហេតុទទួលវត្ថុតាងចុះថ្ងៃទី២៤-០៨-០៦ របស់តំណាងអយ្យការអមតុលាការក្រុងភ្នំពេញ ។

បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ១៣៣១ អយង ចុះថ្ងៃទី ២៣-០៨-០៦របស់ព្រះរាជអាជ្ញាអមតុលាការក្រុងភ្នំពេញ ។

បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ០៣៧ អយង ចុះថ្ងៃទ១០-០១-០៧ របស់ព្រះរាជអាជ្ញាអមតុលាការក្រុងភ្នំពេញ ។

បានឃើញដីកាបញ្ជូនរឿងទៅជំនុំជំរះលេខ:៣៦០ត.ព្រ ចុះថ្ងៃទី ១៥-០១-០៧ របស់ចៅក្រមស៊ើបអង្កេត



Scanned by CamScanner

តុលាការក្រុងភ្នំពេញ ។

បានឃើញដីកាចាត់តាំងចៅក្រមជំនុំជំរះលេខ ១៥៦ គ.ព្រ ចុះថ្ងៃទី១៦-០១-០៧ របស់ប្រធានតុលាការក្រុងភ្នំពេញ ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] thomas បានឆ្លើយថា: ខ្លួនមានប្រពន្ធកូនអាយុ៦ឆ្នាំ មានមុខរបរជា គ្រូបង្រៀនសាលាបញ្ញាសាស្ត្រ រស់នៅផ្ទះលេខ៣៦ E1ផ្លូវ២៧៨ សង្កាត់បឹងកេងកង ខ្លួនរស់នៅជាមួយប្រពន្ធនិងកូនម្នាក់ ហើយខ្លួនបានស្គាល់ [redacted] Heninz រយះពេលពី៣ទៅ៤ឆ្នាំហើយ ។ Henning មិនធ្វើការ គាត់នៅផ្ទះ ។ ខ្លួនធ្លាប់ទៅផ្ទះHenning ៣ខែទៅម្តង ។ ទៅពេលមានបញ្ហាកុំព្យូទ័រ ទៅផ្ទះHenningមិនដែលទៅដេកទេ ។ នៅផ្ទះHenningគ្មានមនុស្សនៅក្រៅពី Henning ។ ថ្ងៃមួយខ្លួនឃើញមិត្តប្រុសអាយុប្រហែល ៤០ ទៅ ៤២ឆ្នាំ ប្រហែលជាអ្នកទេសចរណ៍ហើយគ្មានឃើញស្រីអ្វីទេ ។ មិនអាចទទួលយកពីការចោទប្រកាន់របស់តំណាងអយ្យការឡើយ ។ Henning គ្មានបើកក្លឹបដែរ ។ សមត្ថកិច្ចចាប់ខ្លួននៅក្លោងទ្វាផ្ទះចេញទៅធ្វើការ ។ ខ្លួនជួបជាមួយស្រីវៀតណាម នៅផ្ទះ Henning ។ ខ្លួនគ្មានធ្លាប់រួមភេទជាមួយកុមារនៅផ្ទះ Henning ។ ពីមុនសក់វែងជាងនេះធ្លាប់ចងសក់ដែរ ។ រូបថតខ្លួន ១ទទួលស្គាល់ មានរូបសាក់ ដៃខាងឆ្វេង ។ ដោះអាវចេញតែអត់ធ្លាប់ដោះខោ. រូបស្រាតខោអាវគឺគ្មាន. ពុំធ្លាប់ថតទេ នៅផ្ទះគ្មានស្បៀកក្រមា សំភារះបង្ហាញនេះធ្លាប់ឃើញតែគ្មានស្គាល់ ។ មិនទទួលយកចំលើយនៅតំណាងអយ្យការទេ ព្រោះគ្មានមេធាវី នៅចៅក្រមស៊ើបអង្កេតក៏មិនទទួលយកដែរ. មិនធ្លាប់ឱ្យបៀមលិង្គ ខ្សែកបន្តោងគឺខ្សែកមាស និងបន្តោង ពេលចាប់ខ្លួន ។ គ្មានដីកាចាប់ខ្លួនបង្ហាញទេ ខ្លួនអត់ដឹងថាថតរូបនៅពេលណា មានអ្នកបកប្រែតែមិនបានច្បាស់ នៅអយ្យការមានមេធាវីដែរ . ការសរសេរអក្សដោយផ្ទាល់ដៃគឺជាអក្សរបស់ខ្លួនដែរ ។

-ជនជាប់ចោទឈ្មោះ [redacted] យ៉ីវ បានឆ្លើយថា: ខ្លួនរស់នៅកម្ពុជាមានរយះពេល០៦ឆ្នាំ មានមុខរបរកស៊ីឈ្នួលធ្វើម៉ូតូ ។ Tomas អត់ស្គាល់ តែHenning ស្គាល់៥ឆ្នាំ . ខ្លួនមិនដែលនាំស្រីអោយគេទេហើយ [redacted] ហុងវីង អត់ដែលដែរ ។ ខ្លួននាំក្មេងស្រីយ៉ុងទៅលេងហ្គេមផ្ទះ Henning១០ដង ។ យកឈ្មោះ យ៉ុង មកដោយជិះម៉ូតូឌុប . គ្មានអោយលុយ ឈ្មោះយ៉ុង ដែ . ខ្លួនឱ្យលុយប្តីទៅទិញថ្នាំញៀនចំនួន១០គ្រាប់ ឱ្យលុយ២០ដុល្លា ដើម្បីអោយHenning ។ ឈ្មោះយ៉ុង កន្លងមករស់នៅផ្ទះក្បែរគ្នាជាមួយខ្លួន ។ ពេលនាំឈ្មោះយុង ប្តីខ្លួនទៅជាមួយគ្នា និងនាំក្មេងស្រីក្មេងទៅច្រើន លើក ។

-ជនជាប់ចោទឈ្មោះ [redacted] ឌីបានឆ្លើយថា: ខ្លួនមិននាំក្មេងស្រីទេ ខ្លួនស្គាល់Tomas តែមិនស្គាល់ Henning ខ្លួនមានកូនឈ្មោះ [redacted] ចាន់ធី និង [redacted] ចាន់ថា ជាកូនខ្លួនបង្កើត កូនចាន់ធី ភេទស្រី អាយុ១៣ឆ្នាំ កូនចាន់ថា ភេទស្រី អាយុ១៥ឆ្នាំ ខ្លួនគ្មានទូរស័ព្ទដៃប្រើពេលថ្ងៃខ្លួនចេញទៅរកស៊ី មិនដឹងបាត់កូនទៅណាដែរ ជូនដើររកដែតែរកមិនឃើញ ។ មុនពេលចេញទៅ កូនខ្លួននៅផ្ទះឱ្យអ្នកជិតខាងជួយមើល. អោយកូនទៅរៀនទាំង៣នាក់ ខ្លួនមិនធ្លាប់ទទួលលុយពីកូន ហើយក៏មិនមានអ្វីប្លែកដែរ ។ ខ្លួនគ្មានលក់កូនឱ្យបរទេសឡើយ ។ ខ្លួនស្គាល់ឈ្មោះ [redacted] ធីយ៉ីវ ដែរ ការចោទប្រកាន់របស់តំណាងអយ្យការខ្លួនមិនអាចទទួលយកបាននោះទេ ។ ឈ្មោះហៀង ត្រូវជាប្អូនថ្លៃរបស់ខ្លួននេះ ខ្លួនមិនដែលទទួលលុយចំនួន២០០ដុល្លា ពីឈ្មោះ [redacted] ចាន់ធី . [redacted] ចាន់ថា នោះឡើយ ។ .

-ជនរងគ្រោះឈ្មោះ [redacted] ចាន់ថា បានឆ្លើយថា: ខ្លួនអាយុ១៤ឆ្នាំ ( ឆ្នាំមាន់) ម្តាយឈ្មោះ [redacted] ម៉ុកឌី (រ) ឪពុកឈ្មោះ [redacted] វ៉ាន់លាង (រ) មីងពៅឈ្មោះហៀងប្អូនឪពុក. ហៀងយកអោយទៅឈ្មោះយ៉ីវ ( ស្រី) . យ៉ីវ (ជនជាប់ចោទ) យកខ្លួនអោយ Henning (សក់ខ្មៅ) ប្រហែល៧-៨ដង យ៉ីវអោយលុយ៥០០ដុល្លា ។ រយះពេល៧ថ្ងៃទើបអោយ



Scanned by CamScanner

ត្រឡប់មកផ្ទះវិញ។ លុយ៥០០ដុល្លានេះខ្លួនអោយម្តាយ២០០ដុល្លា មីងហឿងយក៣០០ដុល្លា។ ក្នុងរយៈពេល៧ថ្ងៃគេដោះសំលៀកបំពាក់ ខ្លួនយំមីងពៅគំរាមថាមិនអោយទៅផ្ទះបើយំហើយចាំមាក់នឹងវាយខ្លួនបើខ្លួនទៅវិញ ។ Henning គ្មានអោយថ្នាំលេបឬចាក់ថ្នាំទេ ។ Henning យកខ្សែចងក្រណាត់ពណ៌សចងជើង និងចងដៃកន្ទែកចេញពីគ្នា ខ្លួនឃើញនឹងយកពិលបញ្ចាំងចូលប្រដាប់ភេទ។ Henning យក[redacted]។ Henning ចាប់ចង្កេះរបស់ខ្លួនយកកន្សែងចុកមាត់ខ្លួន ។ Henning . យកប្រដាប់ភេ[redacted]ទៀត ខ្លួនទន់ដៃទន់ជើង ។ ដេកប្រហែល២ម៉ោង ឃើញមានឈាម Henningដេញអោយទៅមុជទឹក ។ Henningធ្វើសញ្ញាល្ងាចម៉ោង៦ចូលបន្ទប់ម្តងទៀតរួមភេទគ្មានចងដៃចងជើងរួមភេទប្រហែល១៥នាទី មានថតរូបភាព Henningជាអ្នកថតដាក់ម៉ាស៊ីនថតមានជើងថតគ្រប់ទាំងអស់រាល់សកម្មភាព ។ គ្មានអោយបាយហូបទេ តែឱ្យហូបនំ។ Henningថតហើយគាត់មើលហើយអោយខ្លួនមើលមិនបានផ្ចិតអោយមើលទេ ។ ១ថ្ងៃ២ដង រួមភេទដេកជាមួយHenning ។ ឈ្មោះ [redacted] ធីយ៉ាវ ទៅផ្ទះ៧ថ្ងៃទើបមកផ្ទះ Henning ។ Henningគាត់ឱ្យខ្លួ[redacted]បាន១ថ្ងៃ[redacted]២ដង[redacted]ហើយទើបរួមភេទ ចេញទឹកប្រឡាក់លើខ្លួនបើមិន[redacted]។ បន្ទាប់មកឈ្មោះ ចាវ បាននាំខ្លួនអោយទៅជួប Tomas ដើម្បីរួមភេទ [redacted]Tomas[redacted]បានទៅTomasព្យាយាម២ដង។ Tomas ឱ្យខ្លួន[redacted]ាប់មានអារម្មណ៍ឆាប់ចេញទឹកកាម ហើយពេ[redacted]ឈ្មោះHenningក៏ដឹងដែ ។ Henningជាអ្នកថតរូបភាព ។ Tomas អោយលុយ១៥ដុល្លា លុយបានហើយមីងពៅយក។ [redacted]ពេលម៉ោង១២អោយ១៥ដុល្លា ហើយម៉ោង៦ល្ងាចអោយ២០ដុល្លា។ លេខ ទូរស័ព្ទ [redacted]លេខថ្មី [redacted]លេខចាស់ ជាលេខទូរស័ព្ទរបស់ម្តាយខ្លួន ។ ខ្លួនស្គាល់ច្បាស់គឺបរទេស២នាក់ បង្ហាញស្គាល់ទាំងអស់ ។ <u>ពីមុនពុំធ្លាប់រួមភេទ</u> ។ ទៅផ្ទះ Henning២ដង ។ អត់ចូលចិត្តរួមភេទទេ ។ ខ្លួនស្គាល់ ចាវ សក់លឿងវែង មីងពៅនាំមកដែរ។ ខ្លួនជួប Tomas លើកទី១នៅ ម៉ោង១២ ទៅម៉ោង០១ លើកទី២ ម៉ោង ៦-៧ យប់ ។

-ជនរងគ្រោះឈ្មោះ [redacted] យ៉ាវ បានឆ្លើយថា: ខ្លួនមានអាយុ១៤ឆ្នាំ រៀនថ្នាក់ទី១នៅមណ្ឌល យ៉ាវនេះមានប្តីឈ្មោះ វៃ ឈ្មោះយ៉ាវ និងប្តីបាននាំខ្លួនដោយប្តីគាត់ជាអ្នកបើកម៉ូតូបានឌុបខ្លួនមកម្តុំផ្សារឡាក់គីផ្ទះ Henning នៅក្រោយផ្សារឡាក់គីដោយយ៉ាវប្រាប់ថាទៅញ៉ាំបង្អែម អង្គុយមួយភ្លែតឱ្យទៅមុជទឹកផ្កាឈូក ប្រាប់អោយយកកន្សែងពណ៌សមានសាប៊ូ ចូលបន្ទប់ទឹក ។ ក្រោយពេលងូតទឹករួចគេក៏ឱ្យចូលបន្ទប់ Henning ក្នុងនោះមានស្រី៣នាក់ក្មេង១ស្លៀកក្រមា បើកភ្លើងមានទូរទស្សន៍មើល។ យ៉ាវ និយាយអង់គ្លេសជាមួយ Henning និងនិយាយវៀតណាមជាមួយខ្លួនហើយឱ្យខ្លួ[redacted]ភេទHenning ពេលរួមភេទគ្មានពាក់ស្រោមទេ ខ្លួនឈឺស្រែកអោយគេជួយគ្មានគេជួយ Henningយកខ្សែខ្មៅចងជើង [redacted]តេចាក់សោទ្វា. ខ្លួនខំរើបំរះតែរើមិនបាន ហើយពុំមានអ្នកជួយ. Henning រួមភេទបានចំនួន៥លើក ១លើកគាត់ឱ្យ១៥ដុល្លា ហើយលុយនោះខ្លួនបានអោយម្តាយ ។ នៅផ្ទះ Henning, Tomas ឱ្យខ្លួន[redacted]២លើក ម៉ោង១:៣០Tomasអោយ១៥ដុល្លា(២ម៉ោង) និងម៉ោង៤ល្ងាចTomasអោយ១៥ដុល្លា ។ Henningអោយលុយខ្លួនចំនួន៣០០ដុល្លា។ Henning បានថត Video ។ ពេលទៅពិនិត្យសុខភាពមានឃើញឈាម ។ កន្លងមកម្តាយខ្លួនមានជំពាក់ប្រាក់គេ ហើយខ្លួនយកប្រាក់នេះឱ្យម្តាយខ្លួនដើម្បីសងប្រាក់ទៅគេ ។

-ជនរងគ្រោះឈ្មោះ[redacted]ចាន់ធី បានឆ្លើយថា: ខ្លួនមានអាយុ១២ឆ្នាំ រៀនពាភាសា ម៉ែឪនៅរស់ ឈ្មោះយ៉ាវមានប្តីឈ្មោះវៃ នៅពេលថ្ងៃពីរនាក់ប្តីប្រពន្ធបានបបួលខ្លួនទៅញ៉ាំបង្អែម ពេលទៅអត់មានបងទៅជាមួយទេទៅដល់ផ្ទះ Henning Henningឱ្យដេកកន្ទែកជើងយកម៉ាស៊ីនថត។ ក៏ជួប Tomasអោ[redacted]ឱ្យលុយចំនួន១៥ដុល្លាគឺនៅ...



Scanned by CamScanner

ផ្ទះHenning ។ Henning បានដាក់ប្រដា[redacted] បានតែបន្តិចទេ ដោយឱ្យ១៥ដុល្លារទៅ២០ដុល្លា ។ Henning រួមភេទជាមួយខ្លួនចំនួន៤-៥ដង លុយដែលបានខ្លួនយកអោយម៉ែ ។Henning ថត Videoអោយខ្លួនចំនួន២០០ដុល្លា ។

-ជនរងគ្រោះឈ្មោះ[redacted]គីមយ៉ុងបានឆ្លើយថា: ខ្លួនមានអាយុ១៣ឆ្នាំ រៀនមតេយ្យ ម្តាយនៅរស់ ឈ្មោះ **យ៉ីវ** ភេទស្រី ជាអ្នកនាំទៅផ្ទះHenning ប្តីខ្លួនមិនស្គាល់ឈ្មោះទេ នៅពេលថ្ងៃប្រហែលម៉ោង២ទាំខ្លួនជាទៅញ៉ាំការ៉េមជាមួយគាត់ ទៅដល់ផ្ទះHenning ហៅអង្គុយហើយឱ្យទៅមុជទឹក មុជទឹកម្នាក់ឯង រួចហៅចូលបន្ទប់ ស្មៀកក្រមារបស់ Henning ឈ្មោះ**យ៉ីវ** បកប្រែភាសាអង់គ្លេសរួចហៅខ្លួ[redacted]Henning[redacted]១ដង រួមភេទ១ដង. ២ដង ។ Henning អោយលុយ**យ៉ីវ**២០ដុល្លា Henningមានម៉ាស៊ីនថត ពេលរួមភេទចងដៃចងជើងរួចថត ។ ខ្លួនបានលុយមកអោយម្តាយខ្លួន ។ ខ្លួនអត់ស្គាល់ Tomas ទេ ។

-ជនជាប់ចោទឈ្មោះ[redacted]**ហុងវីង** បានឆ្លើយថា: ខ្លួនមានអាយុ២១ឆ្នាំ មានប្រពន្ធឈ្មោះ[redacted]**ធីយ៉ីវ** ខ្លួនគ្មានទិញទំប៉ុង ដាំបាយអោយ Henningទេ គ្មានធ្លាប់ទិញគ្រឿងញៀនអោយគាត់ទេ តែខ្លួនយកក្មេងស្រីឈ្មោះ យ៉ុង សាច់ញាតិឆ្ងាយពីខ្លួនអាយុ១៤ឆ្នាំឱ្យHenning ។ ខ្លួនស្គាល់Henning ជាង១ខែមកហើយកន្លងមក ប្រពន្ធខ្លួនធ្វើស្រីខូច ។ Henningអោយប្រពន្ធខ្លួននាំយកឈ្មោះ ចាន់ធី ភេទស្រីឱ្យគាត់ ឬក្មេងតូចៗ ។ ប្រពន្ធខ្លួនជាអ្នកទូរស័ព្ទទៅឈ្មោះ **យ៉ុង**ដោយអោយតំលៃ៣០ដុល្លា ប្រពន្ធខ្លួនបាន១០ដុល្លា **យ៉ុង** បាន២០ដុល្លា ។ ប្រពន្ធខ្លួនទៅច្បារអំពៅនាំ **យ៉ុង** អោយ Henning ហើយ Henningឱ្យខ្លួនទិញថ្នាំញៀន១០គ្រាប់ ។ បន្ទាប់មកសមត្ថកិច្ចចាប់បានខ្លួន ចំលើយនៅប៉ូលីសគឺប៉ូលីសចាប់បង្ខំឱ្យខ្លួនឆ្លើយ និងបង្ខំឱ្យផ្តិតមេដៃ ខ្លួនសុំបដិសេធចំលើយនៅសមត្ថកិច្ច ។

-ជនរងគ្រោះឈ្មោះ[redacted]**ចាន់ធី** បានឆ្លើយថា: ឈ្មោះ[redacted]**ធីយ៉ីវ** និងឈ្មោះ[redacted]ហុងវីង គាត់ជាអ្នកនាំខ្លួនទៅផ្ទះHenning ហើយHenning ចងដៃចងជើងខ្លួន ប្តីប្រពន្ធនៅខាងក្រៅបន្ទប់ Henning កំរៃ១៥-២០ដុល្លា ប្រហែល១ម៉ោងអោយត្រឡប់មកពីបន្ទប់. ៣ថ្ងៃទើបអោយត្រឡប់មកផ្ទះវិញ ខ្លួនមិនបានយកលុយអោយម្តាយទេ ។ ប្តីប្រពន្ធបបួលហូបបង្អែមទៀតទៅម្នាក់ឯងគ្មានបងស្រីទៅជាមួយឡើយ ។ ទៅថ្ងៃធម្មតាមិនមែនថ្ងៃឈប់សំរាក នៅផ្ទះHenning ម្តាយអត់ដឹងទេ ។

-ជនជាប់ចោទឈ្មោះ[redacted]Heninz បានឆ្លើយថា: មកស្រុកខ្មែរ ១០ឆ្នាំហើយ ជួលផ្ទះមួយ៣ឆ្នាំ ឈ្មោះ[redacted]**ហុងវីង** និងឈ្មោះ[redacted]**ធីយ៉ីវ** ខ្លួនធ្លាប់ស្គាល់ ។ ស្គាល់ស្ត្រី[redacted]**ធីយ៉ីវ** ព្រោះជួយធ្វើចំណីអាហារអោយខ្លួន ស្គាល់ប្តីនៅពេលមកជាមួយគ្នាតិចតួចណាស់ដែលស្រីក្មេង២នាក់នេះមកលេងកុំព្យូទ័រ ។ នៅប្រហែល១ម៉ោងខ្លួនឱ្យទៅផ្ទះវិញ ។ ចំពោះថតរូបក្មេងស្រីនេះខ្លួនមិនចងចាំទេ ខ្លួនមានម៉ាស៊ីនថតរូបតែខូចនិងមានជើងទ្រម៉ាស៊ីនថត ។ ផ្ទះជួលនៅក្រោយឡាក់គី មានបន្ទប់នៅម្នាក់ឯង ហើយTomasមកលេងនៅពេលល្ងាចថ្ងៃអាទិត្យ Tomasស្គាល់ឈ្មោះ **យ៉ីវ** ដែរ ។ ខ្លួនមានខ្សែពិយោច្រើន វីកាត់មាន១ . លិខិតឆ្លងដែនមាន ៣ រឺ ៤ .កុំព្យូទ័រ . សៀវភៅរូបភាពតារាចំរៀង. គ្មានរូបថត **ធី ថា និងយ៉ុង** ឡើយ ។ ម៉ាស៊ីនថតខូច១ មានវីដេអូ ម៉ាស៊ីនខូច មានសល់កាសែតខ្លះ ។[redacted]ប្បទិមិត្តមាន១ មានស្រោមអនាម័យមួយប្រអប់ ថ្នាំ KYមួយដប ជាមួយស្រោមអនាម័យ ។ ពេល**យ៉ីវ**នាំក្មេងស្រីមកលេងផ្ទះខ្លួនគ្មានអោយលុយទេ ។ ជំនាញកុំព្យូទ័រដឹងល្មម មានតុក្កតាមួយក្នុងផ្ទះ ។ ឈ្មោះ**ធី ថា និង យ៉ុង** ខ្លួនគ្មានប្រឡែងលេងទេ ។ ខ្លួនធ្លាប់ដេកស្រោតមិនដេកជាមួយក្មេងនេះទេ **កាសែតអាសអាភាសពុំដែលចាក់អោយមើលទេ** ខ្លួនធ្លាប់អោយលុយ៥០០ដុល្លា. ៤០០ ដុល្លា . ៣០០ដុល្លា ទៅ **យ៉ីវ** សំរាប់ទិញថ្នាំព្យាបាលជំងឺ ។ ទទួលស្គាល់រូបថតមុខខ្លួនតែកាត់តបញ្ចូល ។ ខ្លួនគ្មានបានប្រព្រឹត្តបទល្មើសឡើយ មិនបានប្រព្រឹត្តអំពើអានាចារដែរ ក្មេងនោះធ្លាប់ទៅលេងផ្ទះខ្លួនជាច្រើនដង ។ ក្មេងនោះខ្លួនអោយលុយ...



Scanned by CamScanner

៣០ដុល្លា ខ្លួនមិនបានរួមភេទជាមួយទេ ។ Tomas ធ្លាប់យកស្រីមកដេកជូនកាលមនុស្សស្រីក្មេង ជូនកាលមនុស្សស្រីធំ ។ រូបភាពបង្ហាញខ្លួននេះគឺខ្លួនទៅលេងស្រីនៅស្វាយប៉ាក តែស្រីគ្រប់អាយុ ។

**តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា**

ឆ្លងតាមសវនាការសួរដេញដោលនេះឃើញថា ជនរងគ្រោះបានឆ្លើយយ៉ាងជាក់ច្បាស់ ទូវសកម្មភាពរបស់ជនជាប់ចោទ រីឯជនជាប់ចោទបានឆ្លើយបដិសេធទូវទង្វើរបស់ខ្លួន ក្នុងនាមតំណាងអយ្យការសូមតំកល់ដីកាសន្និដ្ឋានស្ថាពរលេខ០៣៧ អយងចុះថ្ងៃទី១០-០១-០៧ របស់ព្រះរាជអាជ្ញាអមតុលាការក្រុងភ្នំពេញ ទុកជាបានការពេញទាំងមូល ។ ហេតុនេះសុំឱ្យចៅក្រមជំនុំជំរះមេត្តាសំរេចទៅតាមច្បាប់ដោយអនុគ្រោះ ។

**មេធាវីការពារសិទ្ធិជនរងគ្រោះបានធ្វើសេចក្តីសន្និដ្ឋានថា**

មេធាវីលោកស្រី [redacted]**សុជារត្ន័** ការពារឱ្យជនរងគ្រោះ ឈ្មោះ[redacted] **ចាន់ធី** ឈ្មោះ [redacted]**ចាន់ថា** ឈ្មោះ [redacted]**យ៉ុង** ឈ្មោះ [redacted] **យីវ** បានសន្និដ្ឋានថា: ការចង រាយដំ និងឱ្យ[redacted] គឺ**Henning , thomas** សរសេរដោយផ្ទាល់ ដៃដោយស្មោះត្រង់ និងមានការស្តាយក្រោយ ។

[redacted]**ធី** ពិតជាបានលក់កូនស្រីឱ្យ **Henning** មែន

-**Henning**ឆ្លើយបដិសេធអត់ស្គាល់ និងអត់ជួបឈ្មោះ **ចាន់ថា និង ចាន់ធី** ។ **Henning** មានមិត្តស្រីមានស្រោមអនាម័យតែ **Tomas** ថាគ្មានមិត្តស្រីទេ ។ **Henning** ថាមិនចេះកុំព្យូទ័រតែ **Hard disk** របស់ **Henning** គឺដោះសោរទៅអាល្លឺម៉ង់ទើបដោះសោរបាន ។ **Henning**ថាគ្មានបង្ហាញដីកាទេ ពេលចាប់ខ្លួនហើយបដិសេធចំលើយនៅមន្ទីរពេទ្យដែលមានប្រធានតុលាការសួរចំលើយ. មេធាវី ហើយមេធាវីអនុញ្ញាតិអោយឆ្លើយ ។ **Henning** ផ្តល់កន្លែងប្រព្រឹត្តបទល្មើស. សំរាប់អោយ **Tomas** នៅផ្ទះរបស់ខ្លួន ។ **Henning** លោតសំលាប់ខ្លួន ព្យាយាមសំលាប់ មានពាក់ពន្ធ័ជាមួយកំហុស. អស់សង្ឃឹមបែបនេះ ។

-**Tomas**ទៅក្នុងសវនាការបដិសេធសំបុត្រសរសេរផ្ទាល់ដៃ គ្មានបានថតរូប គ្មានធ្វើអ្វីទាំងអស់ ។**Tomas** ថាការបង្ហាញរូបថតហាក់ដូចជាមិនមានរូបភាពរបស់ខ្លួន ហាក់ដូចជារៀបចំទុកជាមុន តែរូបថតបានមកពី **Hard disk**ចំនួន៧របស់ **Henning** ហើយរដ្ឋាភិបាលអាល្លឺម៉ង់គេយកចិត្តទុកដាក់លើបង្ហានេះណាស់ ។ **Henning និង Tomas** ថាគ្មានកំហុស តែក្មេងជនរងគ្រោះថាមាន២នាក់ជាអ្នកថតរូបនិងប្រព្រឹត្តអំពើនេះ ។

-[redacted] **ធីយីវ** ខ្លួនអត់ស្គាល់ **Tomas** ។ ចំលើយក្មេង១គឺឈ្មោះ**យីវ**និងប្តី នាំអោយ**Henning** រំលោភនិង[redacted]ហើយក្នុងផ្ទះ**Henning**គ្មានបើកបង្រៀនភាសាអង់គ្លេសទេ ។

[redacted]**ទី** គ្មានរកកូនដែលកូនធ្លាប់បាត់ពីផ្ទះ កូនបានអោយលុយទៅម្តាយ ដោយកូនប្អូនបាត់៣ថ្ងៃ កូនបងបាត់៧ ថ្ងៃ ។ កូនគ្មានលទ្ធភាពរកប្រាក់រាប់រយដុល្លាក្នុង១ខែ១ទេ ។ ពេលបាត់កូនក៏គ្មានដើររកកូនអ្វីទេ ។

-[redacted]**ហុងវីង** នាំក្មេងស្រី១ទៅរៀនភាសាអង់គ្លេសផ្ទះ**Henning**តាមពិតគ្មានបង្រៀនអង់គ្លេស ចំលើយផ្ទុយគ្នា ។ **Henning**អោយលុយ៣០ដុល្លា ស៊ីសង្វាក់ចំលើយ **Henning**ដោយប្រើអោយទិញថ្នាំញៀន ។

-[redacted] **ធីយីវ** ប្រពន្ធ [redacted] **ហុងវីង** គ្រឡាអានចំលើយខ្លួនយល់ព្រមទទួលស្គាល់ ភាពស៊ីសង្វាក់គឺ ប្រពន្ធស៊ីសង្វាក់និង ក្មេងក៏ប្រាប់ថាឈ្មោះ**យីវ** ជាអ្នកបកប្រែឱ្យ **Henning** ។ រូបភាពអាសអាភាស ក្មេងថាប្រ[redacted] ។ **Henning** ចូលចិត្តទៅរួមភេទ កាចសាហាវបំផុត មានកិរិតយល់ដឹងខ្ពស់ ។ ភ័ស្តុតាងដែលប្រមូលបានអានខ្សែគឺ ប្រដាប់ភេទសប្បនិម្មិត ។ ជនបរទេសអាងមានលុយ យកលុយមកឆ្នៀតប្រើលុយលើកុមារី បញ្ជាក់ពីចេតនាហើយមានផ្សាយតាម ខ្សែវីដេ



Scanned by CamScanner

អ្ន តាមរបៀបព្រៃផ្សៃ។ ក្មេងទាំងនេះមានកោសល្យវិច្ច័យពេទ្យបញ្ជាក់ត្រឹមត្រូវ ហើយជាក្មេងក្រោម អាយុ១៥ឆ្នាំ។ មាត្រា ៨ ផ្តល់កន្លែង . ផ្តល់សេវារួមភេទ ដែល **Henning and Tomas** បានប្រព្រឹត្ត ។ **Henning** មើលងាយច្បាប់ ជាន់ឈ្លីច្បាប់ ធ្វើរលោភប្រពៃណី។ ចំពោះ **Henning and Tomas** ~~**និង ធីយ៉ែរ**~~ សុំអោយតុលាការបន្ថែម អនុទោសថែមទៀត។

**<u>មេធាវីការពារសិទ្ធិជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា</u>**

មេធាវី [redacted] **តុលា** ការពារអោយ [redacted] **thomas** បានសន្និដ្ឋានថា: តាំងពីចាប់ដំណើរការពីប៉ូលិស ដល់ពេលជំនុំជំរះកូនក្តីខ្ញុំគ្មានល្មើសអ្វីទាំងអស់។ ប៉ូលិសអាងលើអីទៅចាប់កូនក្តីខ្ញុំ ក្នុងខែ ៧ ខែ ៨ឆ្នាំ ២០០៦នេះ។ គ្មាន វីការឆែកឆេរ. គ្មានភ័ស្តុតាង ថាបានរួមភេទជាមួយក្មេងស្រីបានឡើយ ប៉ូលិសបានរកឃើញក្នុងខែ ២ ឆ្នាំ ២០០៧។ កូនក្តី សរសេរលិខិតសារភាព កូនក្តីខ្ញុំធុញថប់ស្តីប៉ូលិស កូនក្តីខ្ញុំបដិសេធហើយបដិសេធទៀត។ [redacted] **ធីយ៉ែង** និង [redacted] **ហុងវីង** មិនស្គាល់ **Tomas and Henning** ក៏មិនស្គាល់។ កូនក្តីខ្ញុំគាត់គ្មានបានប្រព្រឹត្តអំពើអានាចារ រីឯជនរងគ្រោះ២នាក់ អត់ស្គាល់**Tomas**ទេ។ **Tomas** គាត់បានរួមភេទដែរ តែរួមភេទជាមួយមនុស្សធំ ។ គ្មានភ័ស្តុតាងជាក់ស្តែង គ្មានបទល្មើសជាក់ស្តែង រូបភាព**Tomas and Henning** ដែលបង្ហាញនេះគឺរូបភាពកាត់ត។ **Tomas**គាត់ជាគ្រូបង្រៀន មានលិខិតបញ្ជាក់ពីសាលាថាជាមនុស្សល្អនិងធ្វើការទៀងទាត់ពេលវេលា។ ថ្ងៃធម្មតាហេតុអ្វីកូនក្តីខ្ញុំគ្មានអវត្តមានពីសាលា កូនក្តីខ្ញុំគ្មានបានប្រព្រឹត្តបទល្មើស ហើយមាត្រា ៣៨ នៃច្បាប់រដ្ឋធម្មនុញ្ញ វិមតិសង្ស័យបានផលប្រយោជន៍ទៅជនជាប់ចោទ ខ្ញុំសូមសុំឱ្យតុលាការធ្វើការដោះលែង និងលើកលែងចោទប្រកាន់ ដល់កូនក្តីខ្ញុំ។

មេធាវី [redacted] **ចន្ធា** ការពារអោយ [redacted] **Heninz** បានសន្និដ្ឋានថា: តាមចំលើយបានឆ្លើយយ៉ាងច្បាស់ថា ពុំមានប្រព្រឹត្តអំពើជួញដូរ និងប្រព្រឹត្តអានាចារលើកុមារទេ ។ ជនរងគ្រោះទាំង៤នាក់បានប្រព្រឹត្តអំពើអានាចារមុនរួចហើយ ។ ចំពោះការចងដៃចងជើងជនរងគ្រោះគឺគ្មានទេ កូនក្តីខ្ញុំបានបង្រៀនភាសាអង់គ្លេសដល់ជនរងគ្រោះ។ ចំលើយគ្មានស៊ីសង្វាក់គ្នាមានរៀបចំលើយឱ្យជនរងគ្រោះឆ្លើយដាក់បន្ទុកលើកូនក្តីខ្ញុំ ពិតមានផ្សេង១យកតាមរយៈម៉ូតូឌុប ជាហេតុមិនអាចយកជាការបាន ហេតុដូច្នោះសុំឱ្យតុលាការមេត្តាអោយកូនក្តីខ្ញុំឈ្មោះ**Heninz** រួចផុតពីការចោទប្រកាន់ផង។

មេធាវី [redacted] **ហុង** ការពារអោយ ឈ្មោះ [redacted] **ហុងវីង** ឈ្មោះ [redacted] **ទី** ឈ្មោះ [redacted] **ធីយ៉ែរ** បានសន្និដ្ឋានថា: បែកកូនតែ៥ខែម្តាយឈ្មោះ [redacted] **ទី** មើលកូនមិនស្គាល់តាមរយៈរូបថត និងរូបផ្ទាល់ ។ ជាកំហុសរបស់ឪពុកម្តាយដែលមិនបានមើលថែកូនឱ្យបានត្រឹមត្រូវ ។ ឈ្មោះ [redacted] **ហុងវីង** និងឈ្មោះ [redacted] **ធីយ៉ែរ** ឆ្លើយសារភាពថាខ្ញុំពុំបានប្រព្រឹតទេ មេត្តាលើកលែងចោទប្រកាន់ឱ្យកូនក្តីខ្ញុំផង។

មេធាវី [redacted] **ម៉េងអ៊ី** ការពារអោយ [redacted] **Heninz** បានសន្និដ្ឋានថា: កូនក្តីខ្ញុំពុំបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ពុំមានភ័ស្តុតាងគ្រប់គ្រាន់ចាប់កូនក្តីខ្ញុំទេ ។ ជនរងគ្រោះបានឃុំជាមួយអ្នកផ្សេងទេ ។ មាត្រា៣៨នៃច្បាប់រដ្ឋធម្មនុញ្ញ វិមតិសង្ស័យបានផលប្រយោជន៍ទៅជនជាប់ចោទ សុំអោយដោះលែងកូនក្តីខ្ញុំអោយមានសេរីភាព ច្បាប់ស្តីពីការបង្រ្កាបអំពើជួញដូរមនុស្ស និងអំពើអានាចារមានអនុក្រឹត្យ ច្បាប់នេះកើត ១៩៩៦ គ្មានអនុក្រឹត្យមកលំអិតទេ ហេតុដូច្នោះសុំឱ្យតុលាការមេត្តាអោយកូនក្តីខ្ញុំឈ្មោះ **Heninz** រួចផុតពីការចោទប្រកាន់ផង។

**<u>ជនជាប់ចោទនិយាយសំដីចុងក្រោយ</u>**

-ឈ្មោះ [redacted] **ហុងវីង** ឈ្មោះ [redacted] **ធីយ៉ែរ** ឈ្មោះ [redacted] **ទី** សុំឱ្យតុលាការដោះលែងព្រោះមិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ ។

-ឈ្មោះ [redacted] **thomas** ឈ្មោះ [redacted] **Heninz** ខ្ញុំពិតជាមិនបាន...

ប្រព្រឹត្តអំពើល្មើសទេ គ្មានទោសទេ មេត្តាដោះលែងពូកខ្លួនផង ។ ពូកខ្លួនទាំងអស់គ្នាសុំល្មមពរសុំឱ្យតុលាការមេត្តាជួយរកយុត្តិធម៌ឱ្យខ្លួនផង ។

ក្រោយពីបានស្តាប់ចំលើយឆ្លើយរបស់ជនជាប់ចោទ

ក្រោយពីបានស្តាប់ចម្លើយរបស់ជនរងគ្រោះ

ក្រោយពីបានស្តាប់ការអានចម្លើយរបស់សាក្សី

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានទោសរបស់តំណាងអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិជនរងគ្រោះ

ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**<u>តុលាការក្រុងភ្នំពេញ</u>**

**<u>យល់ឃើញថា</u>**

-តាមរបាយការណ៍សំយោគ របស់ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន លេខ២៨៤-០៦ ចុះថ្ងៃទី ២២-០៨-០៦ ពិតជាមានករណី **ជួញដូរមនុស្ស និងប្រព្រឹត្តអំពើអនាចារលើកុមារ** កាលពីខែកក្កដា . សីហា ឆ្នាំ ២០០៦ នៅក្រុងភ្នំពេញប្រាកដមែន។

-តំណាងអយ្យការសំរេចចោទប្រកាន់ឈ្មោះ [redacted] **ធីយ៉ាវ** ឈ្មោះ [redacted]ទី ឈ្មោះ [redacted] **ហុងរឹង** ឈ្មោះ [redacted] **Heninz** ពីបទ**ជួញដូរមនុស្ស** ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីខែកក្កដា . សីហា ឆ្នាំ២០០៦ តាមមាត្រា ៣ និងនៃច្បាប់ស្តីពីការបង្ក្រាប់អំពើពង្រត់ និងលក់ដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើមនុស្ស និងសំរេចចោទប្រកាន់ ឈ្មោះ [redacted] **Heninz** ឈ្មោះ [redacted]**thomas** ពីបទ **ប្រព្រឹត្តអំពើអនាចារលើកុមា** ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីខែកក្កដា . សីហា ឆ្នាំ២០០៦ តាមមាត្រា ៨ នៃច្បាប់ស្តីពីការបង្ក្រាប់អំពើពង្រត់ និង លក់ដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើមនុស្ស ។

- ជនជាប់ចោទឈ្មោះ [redacted] **ធីយ៉ាវ** និងប្តីឈ្មោះ [redacted] **ហុងរឹង** បាននាំកុមារីចំនួន ៤នាក់ទៅអោយឈ្មោះ [redacted] **Heninz** និង [redacted] **thomas** ដើម្បីបានលក់ព្រហ្មចារិយ៍ និងប្រព្រឹត្តអំពើអានាចារនៅផ្ទះជួលរបស់ **Henning**ផងដែរ ។

- ឈ្មោះ [redacted] **ធីយ៉ាវ** និងប្តីឈ្មោះ [redacted] **ហុងរឹង** បាននាំកុមារីទៅអោយឈ្មោះ **Henning** ដោយប្រើវិធីលួងលោមដូចជាអោយទៅញុាំបង្អែម ការ៉េម រី ដើរលេង និងមានលុយចាយ ។ កុមារីមិនទាន់ចេះបានពិចារណាបានវែងឆ្ងាយគឺជឿលង់សំដីផ្អែមល្ហែមរបស់ [redacted] **ធីយ៉ាវ** ក៏ទៅហើយត្រូវបាន **Henning** ធ្វើទារុណកម្មចងដៃចងជើង និងបានរួមភេទទោះបីកុមារីមានការអង្វរយ៉ាងណាក៏ដោយ ក៏ឈ្មោះនេះនៅតែប្រព្រឹត្តអោយបានសំរេចខាងតែបាន។

-ឈ្មោះ [redacted]**ធីយ៉ាវ** និង **Henning**បានស្គាល់គ្នារយះពេល៥ឆ្នាំមកហើយ ឈ្មោះ[redacted] **ធីយ៉ាវ**នេះឧស្សាហ៍នាំស្រី១ចំយកអោយ**Henning**ដើម្បីរួមភេទ ឈ្មោះ [redacted] **ធីយ៉ាវ** និងបានកំរៃសេវាកម្មក្នុងការនាំយកនោះទៅឱ្យ**Henning** ។ តែឈ្មោះនេះមានបំណងចង់បានប្រាក់ច្រើន គឺរកកុមារីដែលមានវ័យ១២ ទៅ ១៣ និង ១៤ឆ្នាំអោយ **Henning** ហើយ



Scanned by CamScanner

Henning បានផ្តល់ប្រាក់អោយទៅឈ្មោះ [redacted] ធីយ៉ារ រាប់រយដុល្លា ហើយយកអោយកុមារីខ្លះបាន៥០០ដុល្លាខ្លះបាន ៣០០ ដុល្លា និងខ្លះទៀតបាន ២០០ដុល្លា ។

- អំពើនេះហើយគឺជាការលក់ដូរមនុស្ស. ជួញដូរមនុស្សដោយយកមនុស្សកុមារីលក់អោយ **Henning** ហើយ **Henning** ទទួលបានទំនិញហើយត្រូវតែអោយលុយទៅអោយអ្នកយកមក ។

- អ្នកនាំមកគឺជាអ្នកទទួលខុសត្រូវក្នុងការលក់ យកមកត្រូវតែបានកំរៃ ដូច្នេះHenning និង[redacted]ធីយ៉ារ ពិតជាបានតំលៃដូចគ្នា ពិភាក្សារឿងថ្លៃនៅលើការលក់ខ្លួនប្រាណកុមារជាពុំខាន ដូច្នេះអ្នកលក់និងអ្នកទិញមានទោសដូចគ្នា ។

- ឈ្មោះ [redacted] **ធីយ៉ារ** និងប្តីឈ្មោះ [redacted] **ហុងរីង** ជួយសំរួលបែបយ៉ាងក្នុងការនាំកុមារី ជួយដឹកជញ្ជូន ជួយបកប្រែភាសា ជួយនាំឱ្យលេងហ្គេម រកវិធីសាស្រ្តធ្វើឱ្យកុមារីជឿស៊ុបទៅលើអ្នកទាំងពីរ អ្នកទាំងពីរមានគោលបំណងចំគឺ បានប្រាក់ពី **Henning** ដោយយកកុមារីធ្វើជាថ្នូរនិងប្រាក់តែប៉ុណ្ណោះ ។

- ឈ្មោះ [redacted] **ធីយ៉ារ** និងប្តីឈ្មោះ [redacted] **ហុងរីង** នាំយកកុមារីសុទ្ធតែជាអនិតិជនអាយុមិនដល់នៃការទទួលខុសត្រូវខាងផ្លូវច្បាប់គ្រប់គ្រាន់នៅឡើយ ។

- តាមចំលើយរបស់ឈ្មោះ [redacted] **ហុងរីង** ថាខ្លួនពិតជាបាននាំកុមារីឈ្មោះ**យ៉ុង** អាយុ ១៤ឆ្នាំ ជិះម៉ូតូមានគ្នា៣នាក់ ទៅផ្ទះជនបរទេសនៅក្រោយផ្សារឡាក់គីផ្ទះ**Henning** ចំនួន៣ដងមកហើយត្រូវបានឈ្មោះ **Henning** ប្រើអោយទិញថ្នាំយ៉ាម៉ាចំនួន១០គ្រាប់ទៀត ។ ដូច្នេះ [redacted] **ហុងរីង** ដឹងយ៉ាងច្បាស់នូវអំពើដែលខ្លួនបានប្រព្រឹត្តតែឈ្មោះនេះ ម្តងឆ្លើយបដិសេធម្តងឆ្លើយទទួលស្គាល់ចំលើយនៅនគរបាល. អយ្យការ . ចៅក្រមស៊ើបអង្កេត ។

- ឈ្មោះ [redacted] **ធីយ៉ារ** និងប្តី [redacted] **ហុងរីង**បាននាំក្មេងយកទៅអោយ **Henning** ចូលចិត្តរួមភេទជាមួយមនុស្សតូចៗពិសេសកុមារីតែម្តង ។ ហេតុនេះពីរនាក់ប្តីប្រពន្ធ មានគំនិតទុច្ចរិតមានចេតនាទាំងស្រុងដោយយកកុមារីជនជាតិវៀតណាមគ្នាគាត់និយាយស្តាប់គ្នាបាន លក់អោយ **Henning** ។ ការប្រព្រឹត្តទៅលើជនជាតិណាក៏ដោយតែកន្លែងប្រព្រឹត្តនៅលើទឹកដីកម្ពុជា ដូច្នេះហើយជនបរទេសគ្រប់រូបដែលមករស់នៅ វិស្នាក់នៅជាបណ្តោះអាសន្នលើទឹកដីកម្ពុជាអោយតែប្រព្រឹត្តខុសច្បាប់ត្រូវតែគោរព និងអនុវត្តនិងទទួលទោសស្មើៗគ្នានៅចំពោះមុខច្បាប់ ។

- អំពើប្រព្រឹត្តរបស់ឈ្មោះ **Henning** គឺបានប្រើប្រាស់ថ្នាំញៀនមុន ដើម្បីអោយមានអារម្មណ៍របស់ខ្លួនពុះកញ្ច្រោលហ៊ានប្រព្រឹត្តអ្វីៗទាំងអស់ ដូចជាចងដៃកុមារីផ្តោបជាប់គ្នា. ចងជើងអោយកន្ទែកពីគ្នា ធ្វើទារុណកម្មទៅលើខ្លួន ដូចយករំពាត់វាយ. គំរាមកំហែងពាក្យស់ដីជាដើម ទើបធ្វើការរួមភេទជាក្រោយ ជូនកាលបង្ខំអោយកុមារីយកមា[redacted] មិនតែប៉ុណ្ណោះបានថតរូបទុកនៅជាភ័ស្តុតាងទៀតផង ។ ការប្រព្រឹត្តរបស់ឈ្មោះ **Henning** គឺល្មើស និង មាត្រា៣.មាត្រា៨ នៃច្បាប់ស្តីពីការបង្ក្រាបអំពើពង្រត់លក់ដូរមនុស្សនិងអំពើធ្វើអាជីវកម្មលើមនុស្សដែលលោកតំណាងអយ្យការបានចោទប្រកាន់ ២បទល្មើសដោយឡែកពីគ្នា ។ ដូច្នេះ **Henning** ត្រូវទទួលទណ្ឌកម្ម២ទៅតាមនឹងដែរ ។

- អំពើលក់ដូរ និងធ្វើអាជីវកម្មលើកុមារីរបស់ឈ្មោះ [redacted]**ធីយ៉ារ និង** [redacted] **ហុងរីង** ព្រមទាំង **Henning** គឺជាអំពើមួយ ប៉ះពាល់ដល់សណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈសង្គម រំលោភសិទ្ធិកុមារ បំពានសិទ្ធិសញ្ញាអន្តរជាតិស្តីពីកុមារ និងច្បាប់របស់ប្រទេសកម្ពុជា ។ **អំពើនេះគឺមិនអាចអត់អោនអោយបានឡើយ** ។

- ឈ្មោះ [redacted] **នី** ដែលជាម្តាយរបស់ជនរងគ្រោះកុមារី២រូប ឈ្មោះនេះក៏ទទួលបាននូវកំរៃពីការលក់កូន...



Scanned by CamScanner

របស់ខ្លួនក្នុងការលក់ព្រហ្មចារីនោះដែរ គឺលក់អោយជនបរទេស ឈ្មោះ**យឺវ**បានអោយប្រាក់ចំនួន៥០០ដុល្លា ទៅអោយឈ្មោះ [redacted] **ទី** ជាម្តាយកុមារីនេះ ហើយឈ្មោះ**យឺវ**បាន៥០ដុល្លាវិញអោយគាត់ចំនួន៤៥០ដុល្លា ដូច្នេះការលក់កូនអោយទៅបរទេសតាមរយះឈ្មោះ **យឺវ**និងឈ្មោះ**ថាវ** ឈ្មោះ[redacted] ពិតជាបានដឹងក្នុងរឿងនេះ ដោយមានការយល់ព្រមយ៉ាងដូច្នេះ ទើបឈ្មោះ **យឺវ**អាចយកកូនគាត់ទៅបានដែរ ។ ហើយការបន្តបន្ទាប់ឈ្មោ[redacted] **ទី** តែងតែដឹងពីឈ្មោះ**យឺវ** និងឈ្មោះ**ថាវ** លក់កូនអោយទៅរួមភេទជាមួយជនបរទេសបានកំរៃចំនួន ពី១៥ ដុល្លាទៅ ២០ដុល្លានិង ២៥ដុល្លាជាដើម ។

- ឈ្មោះ[redacted] ក៏បានដឹងច្បាស់លាស់ជាកូនស្រីគាត់មួយឈ្មោះ[redacted] **ចាន់ធី**នៅតូចជាងគេ គេមិនបានឃុយក្រមុំទេ គឺលក់អោយ[redacted]នបរទេសតែប៉ុណ្ណោះ ហើយឈ្មោះ[redacted] **ទី** ក៏ទទួលបានកំរៃពីថ្លៃខ្លួន[redacted]**ាន់ ធី** ផងដែរ ។

- ឈ្មោះ[redacted] **ទី** ពិតជាបានលក់កូនទៅអោយជនបរទេសឈ្មោះ **Henning**ដែរ តាមរយះ [redacted] **ធីយឺវ និង** [redacted] **ហុងរឹង** ហេតុនេះឈ្មោះ[redacted] **ទី** ក៏ទទួលខុសត្រូវចំពោះមុខច្បាប់ តាមមាត្រា៣នៃច្បាប់ស្តីពីការបង្ក្រាបអំពើចាប់ពង្រាត់លក់ដូរមនុស្ស និងធ្វើអាជីកម្មលើមនុស្ស ។

- តាមចំលើយកុមារីទាំង៤នាក់ឆ្លើយប្រហាក់ប្រហែលគ្នាថាខ្លួនត្រូវបានឈ្មោះ [redacted]**ធីយឺវ** និងប្តីរបស់គាត់ឈ្មោះ[redacted]**ហុងរឹង**នាំទៅញ៉ាំបង្អែម. ការ៉េម នាំលេងហ្គេម ដោយនាំទៅក្រោយផ្សារឡាក់គី គឺផ្ទះរបស់ **Henning**ដោយ **យឺវ** ជាអ្នកបកប្រែនិងសំរួលប្រាប់អោយធ្វើអញ្ចេះធ្វើអញ្ចុះ ទាំងការចូលទៅមុជទឹក ចូលក្នុងបន្ទប់ . ដោះសំលៀកបំពាក់ឈ្មោះ[redacted]**ធីយឺវ** ជាអ្នកជួយសំរួលបកប្រែនិងណែនាំទាំងអស់ ។.

- តាមការអះអាងរបស់ជនរងគ្រោះបញ្ជាក់ទៀតថា នៅពេលចូលក្នុងបន្ទប់ឈ្មោះ **Henning** បានចាប់ចងដៃអោបជាប់គ្នា ឯជើងចាប់ចងកន្ទែកចេញពីគ្នា ទៅជើងគ្រែនីមួយ១ហើយ **Henning** បានរួមភេទ ដោយបានថតរូបនិងអោយ[redacted] បណ្តាលអោយខ្លួនមានការឈឺចុកចាប់ទោះបីជនរងគ្រោះអង្វរកយ៉ាងណាក៏ដោយ ក៏ជនល្មើសមិនព្រមស្តាប់ការអង្វរកនោះឡើយ ។

- កុមារីឈ្មោះ [redacted] **ចាន់ធី** ដែលមានអាយុតិចហើយនៅតូចជាងគេ **Henning**មិនបានធ្វើការរួមភេទទេគ្រាន់តែអោយកុមារីនោះធ្វើក[redacted] ដោះសំលៀកបំពាក់និងចងដៃចងជើងមើលរូបរាងនិង[redacted]ភេទដូចកុមារីដទៃទៀតដែរ ។

- តាមការចង្អុលបង្ហាញរូបថតគឺកុមារីទាំង៤ បានស្គាល់ច្បាស់រូប **Henning** និង **Tomas** ដែលបានថតស្រាត និងស្គាល់ច្បាស់រូប **Henning** និង **Tomas** ដែលបានថតកំពុងតែរួមភេទ នឹ[redacted]បស់ជនបរទេសទាំង២រូប ។ អ្នកចាត់ចែងថតគឺ**Henning**និង**Tomas** ។ នេះជាភ័ស្តុតាងមួយដែលមិនអាចប្រកែកបានមិនមែនរូបភាពគាត់តដូចជនល្មើសពោលនិងអះអាងនោះទេ ។

- សំភារះប្រើប្រាស់និងឧបករណ៍សំរាប់បំរើផ្លូវភេទគឺជារបស់ **Henning** ហើយទុកដាក់នៅផ្ទះជួលរបស់ **Henning** ដែលសមត្ថកិច្ចអោយធ្វើការឆែកឆេរឃើញថាឧបករណ៍ទាំងអស់នោះសុទ្ធតែថតទុកជាឯកសានៅក្នុងកាសែតវីដេអូក្នុងកាសែត **CD** , **VCD** និង ថតចេញពីម៉ាស៊ីនថតធម្មតាផងដែរ ។ ឧបករណ៍ទាំងអស់នេះតុលាការពិនិត្យពិចារណាដល់បញ្ហានេះមួយណាប្រគល់អោយសាម៉ីខ្លួន មួយណាបំផ្លាញចោល និងមួយណារឹបអូសជាសម្បត្តិរដ្ឋ ។

- ឈ្មោះ **Tomas** ទោះបីមិនបានចូលរួមទិញលក់ដូរកុមារីទាំង៤នាក់នេះក៏ដោយ តែឈ្មោះនេះបានចូល

រួមប្រព្រឹត្តអំពើអានាចារនៅផ្ទះជួលរបស់Henning ដោយបានធ្វើការរួមភេទ និងអោយកុម[redacted]ស់គាត់រហូតដល[redacted]ក្រោយពីគាត់ប្រព្រឹត្តរួច គឺគាត់អោយលុយថ្លៃសេវាកម្មទៅលើកុមារីទាំងនោះខ្លះជូន កាលបាន១៥ដុល្លា ខ្លះទៀតជូនកាលបាន២០ដុល្លា ខ្លះទៀតជូនបាន២៥ដុល្លា ។

- ជាក់ស្តែងរូបថត Tomas នៅក្នុងសៀវភៅគឺសុទ្ធតែរូបអាសអាភាសដែលជាឯកសារ និងភ័ស្តុតាងដែលឈ្មោះនេះមិនអាចធ្វើការប្រកែកបានទេ ។

-ឈ្មោះ Tomas នេះត្រូវបានកុមារីទាំង៤នាក់បានស្គាល់ច្បាស់ ចំហៅមុខមាត់ សក់វែង នៅដើមដៃមានសាក់រូបរាងពស់ គឺឈ្មោះ Tomas ដែលមានវត្តមាននៅទីនេះ គឺជាអ្នកបានប្រព្រឹត្តមកលើខ្លួនប្រាណកុមារី និងអោយកុមារី[redacted]ស់គាត់ ។

- **Henning** និង **Tomas** ដែលកំលាំងសមត្ថកិច្ចធ្វើការឃាត់ខ្លួនដោយមានភស្តុតាងគ្រប់គ្រាន់និងស៊ើប - សង្កាត់ជាមួយជនរងគ្រោះ និងសំភារះប្រើប្រាស់រូបថត និងឯកសារមួយចំនួនទៀតដែលទាក់ទងនិងអំពើអានាចារលើកុមារ ។

- ជនល្មើសទាំងពីរនេះ មុននឹងធ្វើការរួមភេទសុទ្ធតែចងដៃចងជើងកុមារី និងអោយកុមា[redacted]ដូចគ្នា អោយកំរៃសេវាកម្មបំរើផ្លូវភេទដូចគ្នា ។

-អំពើរបស់ជនល្មើសទាំងពីរនាក់ បានធ្វើទៅលើកុមារីវាប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរ កិត្តិយស និងអនាគតរបស់កុមារ ធ្វើអោយកុមារីមើលឃើញភាពពកខ្វក់ គ្មានភាពថ្លៃថ្នូរនៅក្នុងសង្គម ។

- មួយចំណែកទៀត Tomas បានសរសេរលិខិតជាលាយល័ក្ខអក្សរដោយផ្ទាល់ដៃនៅចំពោះមុខសមត្ថកិច្ចថាខ្លួនពិតជា បានប្រព្រឹត្តមែន និងមានការសោកស្តាយនូវកំហុសរបស់ខ្លួនដែលបានប្រព្រឹត្តទៅលើកុមារីនោះ ។ ជាក់ស្តែងជាងនេះទៅទៀត Tomas មានរូបថតជាមួយកុមារីគឺថតស្រាត [redacted] ថតរួមភេទ និងរាល់ចំលើយទាំងអស់ នៅសមត្ថ - កិច្ចទាំងអស់ឃើញថា មានបន្ទុកគ្រប់គ្រាន់ដែលអាចអោយធ្វើការផ្តន្ទាទោសជនល្មើសឈ្មោះ Tomas បានតឹមាត្រា ៨ នៃច្បាប់ស្តីអំពីការបង្ក្រាបលើពង្រត់ និងលក់ដូរមនុស្សនិងអំពើធ្វើអាជីវកម្មលើមនុស្សនេះបាន ។ ចំណែកឯ Henning បានប្រព្រឹត្តអំពើទិញមនុស្សពីឈ្មោះ [redacted] **ធីយីវ** និងឈ្មោះ[redacted]**ហុងវីង** ដើម្បីរួមភេទ ប៉ុន្តែឈ្មោះនេះបានប្រព្រឹត្តបទល្មើសមួយទៀតគឺអានាចារលើកុមារីនៅលើផ្ទះជួលរបស់ខ្លួនដូចមានចំលើយនៅសមត្ថកិច្ច រូបថតនានា និងចំលើយជនល្មើសឈ្មោះ [redacted] **ធីយីវ និង** [redacted] **ហុងវីង** និងចំលើយជនរងគ្រោះ និងភស្តុតាងផ្សេងៗទៀត ដែលសមត្ថកិច្ចធ្វើការរុករកឆែកឆេរសុទ្ធតែជាភស្តុតាងដាក់បន្ទុកលើជនជាប់ចោទឈ្មោះ Henningនេះបានទាំងស្រុង ។

- តាមចំលើយរបស់ជនល្មើសទាំងអស់បានឆ្លើយបដិសេធ មិនហ៊ានទទួលខុសត្រូវចំពោះមុខច្បាប់លាក់-លៀមនូវអំពើទុច្ចរិត ហើយឆ្លើយមានការផ្ទុយគ្នារវាងជនល្មើសនិងជនល្មើសម្នាក់ទៀតដូចជា[redacted]**ធីយីវ និង** [redacted] **ហុងវីង** ថាបាននាំក្មេង១ទៅអោយ Henning តែ Henning បដិសេធ រូបថតHenningស្រាតជាមួយក្មេង ឈ្មោះ Henning ថាហាក់ដូចជាមិនមែនរូបខ្លួនមានគេលួចថត [redacted] **ហុងវីង** ថានាំក្មេង១ទៅគឺអោយទៅរៀនភាសាអង់គ្លេសតែ Henning នៅផ្ទះគាត់គ្មានបើកការបង្រៀនភាសាអង់គ្លេសទេ ។Henning ថាខ្លួនមិនចេះកុំព្យូទ័រអ្វីទេ តែកុំព្យូទ័រHenningមានច្រើន និងរក្សាទុកក្នុងការសំងាត់ដែលគ្មានអ្នកណាមួយចេះនោះឡើយ ។Henning ថាខ្លួនគេមិនដែលបានអោយលុយទៅ[redacted] **ធីយីវ** ទេតែអោយលុយសំរាប់ទិញថ្នាំពេទ្យតែ [redacted]**ធីយីវ** ថាបានទទួលលុយពី Henning ។Henning ថាគ្មានបានថតរូប



Scanned by CamScanner

[redacted] ចាន់ថា, [redacted] ចាន់ធី និង [redacted]មឃ៉ុង ទេ តែជនរងគ្រោះថា Henning បានថតរូបអាសអាភាសជាមួយពួកគេ ។

- សេចក្តីសន្និដ្ឋាន របស់មេធាវីការពារជនរងគ្រោះមានមូលដ្ឋានគ្រប់គ្រាន់គួរអោយតុលាការធ្វើការត្រិះរិះពិចារណាបានតែមេធាវី បានសំណូមពរអោយតុលាការផ្តន្ទាទោសបន្ថែមត្រង់ចំនុចមាត្រា ៤ មាត្រា [illegible] តុលាការមិនអាចធ្វើការផ្តន្ទាទោសតាមសំណូមពររបស់មេធាវីនោះទេ ព្រោះថាតុលាការធ្វើការជំនុំជំរះបានទៅលើតែបទចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរ របស់តំណាងអយ្យការតែប៉ុណ្ណោះ ដូចមាត្រា១០៤នៃច្បាប់នីតិវិធីព្រហ្មទណ្ឌបានចែងច្បាស់ហើយតែតុលាការយល់ថា ការផ្តន្ទាតាមដីការសន្និដ្ឋានស្ថាពររបស់តំណាងអយ្យការ គឺសាកសមណាស់ទៅហើយ ។ ចំណែកឯមេធាវីការពារអោយជនជាប់ចោទទាំងអស់ថា កូនក្តីរបស់គាត់មិនបានប្រព្រឹត្តអំពើដូចតំណាងអយ្យការធ្វើការចោទប្រកាន់នោះទេ មេធាវីបានលើកហេតុផលជាច្រើនដូចជាថាមិនមែនជាបទល្មើសជាក់ស្តែង ការចាប់ខ្លួនក៏គ្មានដីកា ការឆែកឆេរគ្មានឃើញវត្ថុតាង វីភស្តុតាង ។ ដូច្នេះជារឿងប្រឌិតតែប៉ុណ្ណោះ ចំលើយនៅសមត្ថកិច្ចប៉ូលីសគឺជាចំលើយគេចាប់បង្ខំ លិខិតសរសេរដោយផ្ទាល់ដៃ ក៏ជាការចាប់បង្ខំរបស់សមត្ថកិច្ចនោះដែរ ចំលើយជនរងគ្រោះឆ្លើយមិនច្បាស់លាស់ម្តងថាអញ្ចេះម្តងថាអញ្ចុះ ចំលើយទាំងនោះ ហាក់ដូចជាមានការរៀបចំឡើងដោយមាននរណាម្នាក់នៅពីក្រោយជនរងគ្រោះមិនដែលស្គាល់ជនល្មើស ថាជនរងគ្រោះ បានប្រព្រឹត្តខិលខូចមុន Henning, Tomas មុនរួចទៅហើយ. ចំលើយគ្មានស៊ីសង្វាក់គ្នា លេខសំងាត់ទើបតែរកឃើញថ្មី១នេះ តែការចោទប្រកាន់មុនរួចទៅហើយ កោសល្យវិច្ច័យទើបតែធ្វើជាដើម ។ មេធាវីសំណូមពរអោយតុលាការធ្វើការលើកលែងការចោទប្រកាន់កូនក្តីរបស់គាត់ទាំងអស់ និងដោះលែងកូនក្តីអោយគាត់មានសិទ្ធិសេរីភាព ។ រាល់ការលើកឡើងរបស់មេធាវីគឺការដោះបន្ទុកអោយកូនក្តីរបស់គាត់ ហើយគាត់ពុំមានភស្តុតាងណាផ្សេងនោះឡើយ គឺមានលិខិតបញ្ជាក់ពីសាលាមួយច្បាប់តែប៉ុណ្ណោះ ក៏មិនមានលក្ខណះគ្រប់គ្រាន់នោះដែរ។ រាល់ចំនុចរបស់មេធាវីការពារអោយជនជាប់ចោទ តុលាការ ក៏ធ្វើការត្រិះរិះពិចារណាដែរ ។

- **Henning and Tomas** ជាជនជាតិអាល្លឺម៉ង់ដូចគ្នាបានប្រព្រឹត្តល្មើសនឹងច្បាប់នៅក្នុងប្រទេសកម្ពុជា ដោយចាត់ទុកថាប្រទេសកម្ពុជា ជាប្រទេសទន់ខ្សោយប្រើជាកន្លែងល្បែងកំសាន្ត ស្រីស្រា គ្រឿងញៀន អានាចាជាដើម ។ យកប្រាក់ដុល្លាធ្វើជាអន្ទាក់អូសទាញ [redacted]ធីយ៉ាវ, [redacted]ហុងវ៉ៃ, [redacted] នី ជាជនជាតិវៀតណាម ហ៊ានលក់ក្មួយ កូនអោយប្រព្រឹត្តបទល្មើសផ្ទុយពីច្បាប់ ហើយអ្នកទាំងនេះក៏នឹងទទួលទោសរបស់ប្រទេសកម្ពុជាផងដែរ ។ តែឈ្មោះ **Henning** មានវ័យចំណាស់ជាងគេគឺ៦១ឆ្នាំ ហើយទទួលទណ្ឌកម្មពីរបទល្មើសម្នាក់ឯងហើយយូរឆ្នាំជាងគេដែរ ។

- មានភស្តុតាងគ្រប់គ្រាន់ដែលសមត្ថកិច្ចប្រមូលបាន ដែលអាចអោយធ្វើការផ្តន្ទាទោសជនជាប់ចោទទាំងអស់នេះបាន ។

**ហេតុដូច្នេះ**

**<u>វិនិច្ឆ័យសេចក្តី</u>**

**១/ ផ្តន្ទាទោស :**

ក-ឈ្មោះ [redacted]ធីយ៉ាវ ភេទស្រី អាយុ២២ឆ្នាំ ជាតិវៀតណាម

ខ-ឈ្មោះ [redacted]ហុងវ៉ៃ ភេទប្រុស អាយុ២០ឆ្នាំ ជាតិវៀតណាម

ដាក់ពន្ធនាគារកំណត់ក្នុងម្នាក់១ ចំនួន១៧ឆ្នាំ ដប់ ប្រាំពីរឆ្នាំ គិតចាប់ពីថ្ងៃចាប់ខ្លួនថ្ងៃទី១៩-០៨-២០០៦ ។

គ-ឈ្មោះ [redacted] នី ភេទស្រី អាយុ៤៨ឆ្នាំ ជាតិ វៀតណាម ដាក់ពន្ធនាគារកំណត់១៥ឆ្នាំ ដប់ប្រាំ ឆ្នាំ



Scanned by CamScanner

គិតចាប់ពីថ្ងៃចាប់ខ្លួនថ្ងៃទី១៩.០៨.២០០៦ ។

ឃ-ឈ្មោះ [redacted] **Heninz** ភេទប្រុស អាយុ៦០ឆ្នាំ ជាតិអាឡឺម៉ង់ ដាក់ពន្ធនាគារកំណត់១៦ឆ្នាំ "ដប់ប្រាំមួយឆ្នាំ" គិតចាប់ពីថ្ងៃ ចាប់ខ្លួនថ្ងៃទី១៩-០៨-២០០៦ ។

ពីបទ : **ជួញដូរមនុស្ស** ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីខែកក្កដា . សីហា ឆ្នាំ២០០៦ ។ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៣ នៃច្បាប់ស្តីពីការបង្ក្រាបអំពើពង្រត់ និងលក់ដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើមនុស្ស ។

**២/ ផ្តន្ទាទោស :**

ក-ឈ្មោះ [redacted] **Heninz** ភេទ ប្រុស អាយុ៦០ឆ្នាំ ជាតិអាឡឺម៉ង់ ដាក់ពន្ធនាគារកំណត់១២ឆ្នាំ "ដប់ពីរឆ្នាំ" គិតចាប់ពីថ្ងៃផុតកំណត់ ទណ្ឌកម្មនៃបទល្មើសក្នុងចំណុច១ខាងលើនេះ ។

ខ-ឈ្មោះ [redacted] **thomas** ភេទប្រុស អាយុ៤២ឆ្នាំ ជាតិអាឡឺម៉ង់ ដាក់ពន្ធនាគារកំណត់១២ឆ្នាំ "ដប់ពីរឆ្នាំ" គិតចាប់ពីថ្ងៃ ចាប់ខ្លួនថ្ងៃទី២១-០៨-២០០៦ ។

ពីបទ: **ប្រព្រឹត្តអំពើអានាចារលើកុមារ**ប្រព្រឹត្តនៅ ក្រុងភ្នំពេញ កាលពីខែកក្កដា .សីហា ឆ្នាំ២០០៦ ។ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៨នៃច្បាប់ស្តីពីការបង្ក្រាបអំពើពង្រត់ និងលក់ដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើមនុស្ស ។

**៣/** វត្ថុតាង :

ក-លិខិតឆ្លងដែនមានលេខ ១/ ៣៣៤៥០០៥៤ ៤០. ២/៩៥០៦៣៧៥៧៣៥ . ៣/ ១០៣២១ ៣៦៨៤០ . ៤/ ១០៣២០៧៧៧៤៥. ៥/ ១០ ៣២០៩៨៥៤៨. ៦/ ១៣១០២៨៤៤០១ លិខិត ឆ្លងដែនចំនួន០៦ក្បាលត្រូវប្រគល់អោយសាម៉ីខ្លួនវិញ ក្រោយពេលផុតកំណត់ទណ្ឌកម្មរួច។

ខ- **VCD .CD**កាសែត **Mini DV**លេខ **60**ម៉ាក **Sony**ចំនួន៤៣ដុំ . ខ្សែពណ៌សប្រវែង០៥ម៉ែត្រ "ប្រាំម៉ែត្រ" មួយខ្សែ . ខ្សែពណ៌ផ្កាឈូកប្រវែង ០២ម៉ែត្រ "ពីរម៉ែត្រ" មួយខ្សែ . រំពាត់ស្បែក ចំនួនមួយ . [redacted]និមិត្តចំនួន០៦ . ថ្នាំម៉ាក **KY** ១ដប . សៀវភៅរូបអាសអាភាសមួយចំនួន .ហ្វីលរូបអាសអាភាសមួយចំនួន . ស្រោមអានាមយ័មួយចំនួន ត្រូវរឹបអូសនិងបំផ្លាញចោល ។

គ- ម៉ាស៊ីនថតរូបម៉ាក **Kodark** ចំនួនមួយ . កាមេរ៉ាថតវីដេអូម៉ាក**Sony 1.5 Magapixel** ចំនួនមួយ . **P C card** ចំនួនមួយ . ម៉ាស៊ីនថត រូបម៉ាក**Olympus** ចំនួនមួយ . **Platininnum card** ចំនួនមួយ . **ID card** ចំនួនមួយ . ម៉ាស៊ីន ថតវីដេអូម៉ាកសូនី ចំនួនមួយ . ទូរស័ព្ទដៃម៉ាក ណូគារ ចំនួនមួយ . ធុងបាស់តូចម៉ាក **Nicole** ចំនួនពីរ . ម៉ូនីទ័រម៉ាក**Socos** ចំនួនមួយ . ស្កេនន័រ ម៉ាក **HP4850** ចំនួនមួយ . ម៉ៅកុំព្យូទ័រ ចំនួន មួយ . រូបតុក្កតាក្មេងលេងចំនួនមួយ . **PCM CIA Fax Modem** ចំនួនមួយ . **CD Rom code DVR** ចំនួនមួយ . ឌីសកុំព្យូទ័រ៣០បន្ទះ . ប្រដាប់ទប់ភ្លើងកុំព្យូទ័រ ចំនួនមួយ ត្រូវរឹបអូសទុកជា សម្បត្តិរដ្ឋ ។

សាលក្រមនេះជំនុំជំរះនៅថ្ងៃទី ១៦-០២-២០០៧ . ០៩-០៣-២០០៧ និង ប្រកាសជាសាធារណៈនៅថ្ងៃទី០៩-០៣-២០០៧ ចំពោះមុខជនជាប់ចោទ.ជនរងគ្រោះ និង មេធាវី បើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ**

[redacted]

**ចៅក្រមជំនុំជំរះ**

[redacted]



Scanned by CamScanner